# សកម្មភាពសហគមន៍

“ឆ្លងកាត់គ្រប់យ៉ាងទាំងការរីកចម្រើនខាងឧស្សាហកម្ម និងការប្រែប្រួលចំពោះទន្លេ វានៅតែបន្តហូរ ទាំងទឹកទន្លេ ទាំងព្រលឹងរបស់ប្រជាជនដែលបានស្រលាញ់វា"។

លោក James Rasmussen, ទន្លេអមត

South Park គឺជាសហគមន៍មួយដែលយកចិត្តទុកដាក់ចំពោះកន្លែងដែលពួកគេរស់នៅ ធ្វើការ និងលេង។ មុនពេលអាចចូលឆ្នេរទន្លេនេះបាន អ្នកស្រុកប្រាថ្នាចង់បានយុត្តិធម៌បរិស្ថាន និងការស្តារឡើងវិញ ដែលភ្ជាប់មនុស្សជាមួយទន្លេ និងជាមួយគ្នាទៅវិញទៅមក។

បន្ទាប់ពីការបំពុលដោយឧស្សាហកម្ម និងការកសាងក្រុង 100 ឆ្នាំមក តំបន់នេះត្រូវបានចាត់ថ្នាក់ជាទីតាំង Early Action Superfund ដោយទីភ្នាក់ងារការពារបរិស្ថានសហរដ្ឋអាមេរិក។ ការសម្អាតវត្ថុធាតុគ្រោះថ្នាក់ជាបន្ទាន់ត្រូវបានទាមទារ។ សហគមន៍ជ្រលងភ្នំ Duwamish Valley បានឃើញសក្តានុពលនៅក្នុងផែនការមាត់ទន្លេ និងកំពង់ផែដំបូងដ៏ចម្រូងចម្រាសនេះសម្រាប់ការប្រើប្រាស់ខាងឧស្សាហកម្ម។ កំពង់ផែបានយល់ព្រម។ ការសម្អាតបានចំណាយពេលប្រាំឆ្នាំ ដោយបញ្ចប់នៅខែធ្នូ ឆ្នាំ 2014។ ការចូលដល់ឆ្នេរទន្លេ និងការកែលម្អជម្រកនៅតាមពាមបានបន្ត ហើយឧទ្យានបានបើកទ្វារទទួលសាធារណជននៅរដូវក្តៅ ឆ្នាំ 2022។

ដែនជម្រកតាមឆ្នេរ និងឧទ្យានប្រជាជនទន្លេ Duwamish River ឥឡូវនេះគឺជាទ្រព្យរបស់សហគមន៍ និងបរិស្ថានដែលរៀបចំដោយមនុស្សជាច្រើន។ យើងគោរពដល់ដូនតាដើមដែលបានប្រមូលផ្តុំគ្នាតាំងពី 10,000 ឆ្នាំមុននៅកន្លែងនេះ។ យើងអបអរសាទរការស្តារឧទ្យានឱ្យស្អាត មានសុវត្ថិភាព និងគួរជាទីស្វាគមន៍។ យើងសូមអញ្ជើញអ្នកទាំងអស់គ្នាមកជួបជុំគ្នា ស្វែងយល់ និងការពារដោយនាំយកគុណតម្លៃវិជ្ជមានបន្តទៅទៀតឱ្យបានយូរអង្វែង។

## ប្តេជ្ញាចំពោះទន្លេ

"បរិស្ថានចាប់ផ្តើមពីបាតជើងរបស់អ្នក។ អ្នកជាប់ពាក់ព័ន្ធនឹងបរិស្ថាននៅរាល់ពេលដែលអ្នកបោះជំហាន"។

លោក John Beal

លោក John Beal ជាអ្នកស្រុកនៅ South Park ដែលបានស្លាប់ ត្រូវបានគេហៅថាជាវីរជនដើមម្នាក់ក្នុងការស្តារទន្លេនេះឡើងវិញ។ គាត់បានប្រើទូកផ្ទាល់ខ្លួនរបស់គាត់ដើម្បីយកសំរាមចេញពីមាត់ទឹក បានអប់រំមនុស្សជាច្រើនអំពីទន្លេ Duwamish River និងបានបំផុសអ្នកជិតខាងរបស់គាត់ឱ្យចែករំលែកក្តីប្រាថ្នា និងការតស៊ូមតិរបស់គាត់សម្រាប់បរិស្ថាន។



Tom Reese

លោក John Beal រឹតតែខិតខំមើលការខុសត្រូវទន្លេ Duwamish River នៅពេលគេប្រាប់គាត់ថា គាត់រស់បានតែបួនខែទៀត។ គាត់បានបង្កើតឥទ្ធិពលដល់គ្រប់កន្លែងនៃទន្លេនេះសម្រាប់រយៈពេល 27 ឆ្នាំក្រោយមក។ គាត់បានបង្កើតមូលនិធិការពារជីវិតសត្វក្នុងទឹកនៃសមាគមសមុទ្រអន្តរជាតិ (I'M A PAL) ដែលជាមូលនិធិមួយធានាឱ្យមានការដឹកនាំការយកចិត្តទុកដាក់ ធនធាន និងការថែទាំដើម្បីស្តារព្រែក Hamm Creek។

គាត់ជាអ្នករៀបចំ និងជាអ្នកដឹកនាំដែលបានគាំទ្រការស្តារឡើងវិញ និងការសម្អាតទន្លេឱ្យខ្លាំងក្លាតាមរយៈក្រុមសម្ព័ន្ធភាពសកម្ម Duwamish ក្រុមសម្ព័ន្ធភាពសម្អាតទន្លេ Duwamish River, ECOSS, ក្រុមអភិរក្សនៃអតីតយុទ្ធជន និងច្រើនទៀត។ កេរដំណែលរបស់លោកJohn Beal បន្តបំផុសយុវជន និងសមាជិកសហគមន៍នៅក្នុងជ្រលងភ្នំDuwamish Valley ឱ្យធ្វើសកម្មភាពដើម្បីបរិស្ថានដល់សព្វថ្ងៃនេះ